គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៤១៦ សរណ គ.ជ.អ.ប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកកិច្ចសន្យា និងទីប្រឹក្សាដែលបំពេញការងារក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**យោង:** សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់ គ.ជ.អ.ប និងកិច្ចសន្យាការងាររបស់បុគ្គលិក ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា ផ្អែកតាមការណែនាំដែលមានចែងក្នុងសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់ គ.ជ.អ.ប បានកំណត់ការវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកក្នុងក្របខណ្ឌជអ៣ ដើម្បីពិនិត្យឡើងវិញលើការបំពេញការងាររបស់បុគ្គលិកដោយធ្វើការផ្ទៀងផ្ទាត់ជាមួយលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ៗ។ ការវាយតម្លៃនេះរួមមាន៖ ការវាយតម្លៃការអនុវត្តកិច្ចសន្យាការងារប្រចាំឆ្នាំ និងការវាយតម្លៃការអនុវត្តកិច្ចសន្យាសាកល្បងការងារ ដែលអនុវត្តចំពោះទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំដំណើរការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកទាំងអស់ ដែលកំពុងបំពេញភារៈកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុលោមតាមគោលការណ៍ណែនាំដូចភ្ជាប់មកជាមួយ។ ចំពោះការវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សាថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ត្រូវប្រើប្រាស់ទម្រង់បែបបទវាយតម្លៃសម្រាប់ទីប្រឹក្សា (ឧបសម្ព័ន្ធទី១) និងបុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី២-ក)។ បុគ្គលិកកិច្ចសន្យារួមមាន៖ បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត និងបុគ្គលិកគាំទ្របច្ចេកទេសក្រុង ស្រុក ។ ការវាយតម្លៃការបំពេញការងាររបស់អ្នកបើកបរ ត្រូវប្រើប្រាស់ទម្រង់បែបបទវាយតម្លៃសម្រាប់បុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី២-ខ)។ បន្ទាប់មក រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី៤សម្រាប់ទីប្រឹក្សា និងឧបសម្ព័ន្ធទី៥សម្រាប់បុគ្គលិកកិច្ចសន្យា) និងឯកសារវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា ដើម្បីបញ្ជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប។

លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើឯកឧត្តមមេត្តារៀបចំដំណើរការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកដូចដែលបានកំណត់ខាងលើ ហើយផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប នូវរបាយការណ៍សង្ខេប និងសំណុំឯកសារវាយតម្លៃ ឱ្យបានមុន**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦** ជាកំណត់។ ដោយឡែក

ចំពោះបុគ្គលិកកិច្ចសន្យា និងទីប្រឹក្សាដែលត្រូវបញ្ចប់កិច្ចសន្យាសាកល្បងការងារ ក៏ត្រូវវាយតម្លៃឱ្យបានមុន ដំណាច់ខែធ្នូ ឆ្នាំ២០១៦ នេះផងដែរ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ចាត់ចែងអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**